# បដិមាទេពប្រុសរកឃើញនៅប្រាសាទព្រៃបាសាក់ ខេត្តស្វាយរៀង

ប្រាសាទព្រៃបាសាក់ មានចម្ងាយត្រឹមតែ ៥គីឡូម៉ែត្រ ប៉ែកអាគ្នេយ៍ទីរួមខេត្តស្វាយរៀង ដែលស្ថិតនៅត្រង់ភូមិបាសាក់ ឃុំបាសាក់ ស្រុកស្វាយជ្រុំ។ យោងឯកសាររបស់លោក Lunet de Lajonquière បានឱ្យដឹងថា នៅឆ្នាំ១៩០១ - ១៩០២ លោក Jean Commaille បានធ្វើកំណាយបុរាណវិទ្យានៅទីនេះ ដោយបានរកឃើញប្រាសាទកណ្ដាលធ្វើអំពីឥដ្ឋចំនួនមួយ ភ្ជាប់ជាមួយសាលវែងមួយ បែរមុខទៅទិសខាងកើត និងប្រាង្គតូចៗធ្វើអំពីឥដ្ឋចំនួន ៧ទៀតហ៊ុមព័ទ្ធជុំវិញ។ នៅប្រាង្គកណ្ដាល គេធ្លាប់រកឃើញបដិមាធ្វើថ្មភក់ និងសំរឹទ្ធជាច្រើន។ វត្ថុសិល្បៈដែលរកឃើញតាមរយៈការធ្វើកំណាយទាំងនោះ គេបានយកទៅរក្សាទុកនៅសាលាខេត្ត និងក្រោយមកទៀតវត្ថុមួយចំនួនបានបញ្ជូនមកកាន់សារមន្ទីរជាតិកម្ពុជា នារវាងចុងទសវត្សរ៍១៩១០។ ក្នុងចំណោមវត្ថុបុរាណដែលបានចល័តមកកាន់សារមន្ទីរជាតិកម្ពុជា មានបដិមាទេពប្រុសចំនួន ១អង្គ ដែលអ្នកស្រាវជ្រាវជាទូទៅយល់ថាជា "រូបព្រះសិវ" ឬខ្លះយល់ថាជា "រូបព្រះសិវក្នុងទម្រង់ជារាជវង្ស"។ តើបដិមានេះមានប្រវត្តិ និងលក្ខណៈដូចម្ដេចខ្លះ?

បដិមានេះកសាងឡើងអំពីថ្មភក់ មានកម្ពស់ ១៦៧ស.ម. ទទឹង ៨៣,៥ស.ម. កម្រាស់ ៥៤,៥ស.ម. និងទម្ងន់ ៤៧៩គ.ក.។ ដោយសារតែ បដិមានេះបានមកដល់សារមន្ទីរជាតិកម្ពុជាយូរមកហើយ នាំឱ្យលេខបញ្ជីសារពើភណ្ឌសម្រាប់បដិមានេះមានច្រើនលើកច្រើនសា ដាក់ស្ដែងលោក George Groslier ចុះបញ្ជីលេខ B.112, លោក Jean Boisseiler ចុះលេខ B.60.1 និងពីរដងទៀតមានលេខ Ka.1682, ខ.94។ តាមរយៈឯកសារលោក Jean Commaille កាលពីឆ្នាំ១៩០២ ទំព័រ ២៦៦ បានពណ៌នាថា "មានរូបសំណាកព្រះសិវធ្វើអំពីថ្មភក់ គង់បញ្ឈរដង្គង់ខាងស្ដាំ បត់ជើងខាងឆ្វេងរាបស្មើ ព្រះហស្តស្ដាំកាន់កេតនកណ្ដាអ្វីមួយតែបាត់បង់, ព្រះហស្តឆ្វេងដាក់លើភ្លៅ ព្រះកាយទទេគ្មានគ្រឿងអលង្ការ ស្លៀកសំពត់ខ្លី និងមានព្រះនេត្រទីបីនៅលើថ្ងាស"។ សំណេរនេះ នាំយើងដឹងថា លោក Jean Commaille ជាបុគ្គលដំបូងដែលសន្និដ្ឋានថា បដិមានេះជាព្រះសិវ តែលោកមិនបានបញ្ជាក់ហេតុផលអ្វីឡើយ ពោល ប្រហែលជាលោកយោងទៅលើព្រះនេត្រទីបីនៅលើថ្ងាសក៏អាចថាបាន។ ក្រោយមក បដិមានេះ ត្រូវបានសិក្សាជាបន្តបន្ទាប់ ជាពិសេស ការសិក្សារបស់លោក Jean Boisseiler (ឆ្នាំ១៩៥៥) និងលោក Nadine Dalsheimer (ឆ្នាំ២០០១)។ លោកទាំង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ពីរយល់ថា បដិមានេះ ជាព្រះសិវក្នុងទម្រង់ជាពជវង្ស ដោយព្រះបាទខាងឆ្វេងដាក់ជាប់ដី និងខាងស្ដាំលើកឡើងលើ (កាយវិការអង្គុយរបៀបនេះ គេស្គាល់ថា "**មហារាជលីលាសន**")។ លោក Nadine Dalsheimer យល់ថា ព្រះកេសា និងព្រះភក្រ្តរបស់បដិមានេះ រៀបចំឡើងយ៉ាងឥតខ្ចោះ ដែលបង្ហាញនូវអំណាច និងកម្លាំងដ៏អស្ចារ្យ ហើយកាន់តែទាក់ទាញខ្លាំងឡើងជាមួយនឹងត្បូងពេជ្រដែលបង្កប់នៅក្នុងព្រះនេត្រទីបី។ លោកទាំងពីរយល់ថា បដិមាព្រះសិវនេះកសាងឡើងនៅពាក់កណ្ដាលទី២ នៃស.វ.ទី១១ ដែលត្រូវនឹងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (សម័យអន្តរកាលរវាងរចនាបថឃ្លាំង និងរចនាបថបាភួន)។ ការសន្និដ្ឋានអាយុកាលនេះ គឺត្រូវគ្នាជាមួយនឹងអាយុកាលដែលបានដាក់នៅក្នុងស្លាកព័ត៌មានរូប (Label) តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា។

ដើម្បីស្វែងយល់ព័ត៌មានបន្ថែមអំពីប្រវត្តិបដិមានេះ យើងសាកល្បងពិនិត្យសិលាចារឹកដែលបានរកឃើញនៅប្រាសាទព្រៃបាសាក់ ដែលកន្លងមកគេធ្លាប់រកឃើញចំនួន ៤ ផ្ទាំង (K.69, K.70, K.71, K.425)។ ក្នុងនោះ សិលាចារឹកមានលេខបញ្ជី K.69 គឺចារឹកជាភាសាសំស្រ្កឹត ប៉ុន្តែដោយសារតែរលុបអក្សរជាច្រើន គេមិនអាចយល់អត្ថន័យជារួមបានឡើយ ប៉ុន្តែ នៅក្នុងកំណាព្យស្លោកទី៤ នៃសិលាចារឹក គឺបានរំលេចអំពីព្រះនាមព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៤៩)។ ដោយសារតែមានរំលេចព្រះនាមអង្គ បូករួមទាំងអក្សរមានលក្ខណៈជាទម្រង់អក្សរស.វ.ទី១១ផងនោះ នាំឱ្យលោក George Coedès គិតថា សិលាចារឹកនេះទំនងចារឹកឡើងនៅរាជ្យរបស់ទ្រង់។ ម៉្លោះហើយ តើអាចទេដែលថា បដិមាដែលគេយល់ថាជាព្រះសិវដូចបានរៀបរាប់ខាងលើ កសាងនៅក្នុងរាជ្យរបស់ទ្រង់ ឬតំណាលសិលាចារឹកនេះ? ចំណែក សិលាចារឹក មានលេខបញ្ជី K.70 បានផ្ដល់ព័ត៌មានច្រើនជាងសិលាចារឹកទាំងបីផ្សេងទៀត ពោល គឺមានចារឹកជាស្លោកសំស្រ្កឹតផង និងសំណេរភាសាខ្មែរផង។ សិលាចារឹកនេះ ចារឹកឡើងនៅក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧) ដែលរៀបរាប់ពោលសរសើរអំពីវីរភាពរបស់ព្រះបាទរាជេន្ទ្រវរ្ម័ន និងមន្ត្រីជំនិតមួយរូបរបស់ទ្រង់ឈ្មោះ "ន្ទ្របេន្ទ្រយុទ្ធ" រួមទាំងការកសាងប្រាសាទមួយកន្លែងថ្វាយដល់ទេពព្រះនាម "**វកកាកេស្វរ**"។ លោក George Coedès យល់ថា "**វកកាកេស្វរ**" ជាព្រះនាមសំស្រ្កឹត ត្រូវនឹងភាសាខ្មែរថា "**កំម្រតេង ជគត វក ឯក**" ដែលបានរំលេចនៅក្នុងសិលាចារឹកមួយផ្ទាំងទៀត លេខបញ្ជី K.425 ហើយជាឈ្មោះដើមរបស់ប្រាសាទ ឬជាព្រះនាមសិវលិង្គដែលតម្កល់នៅប្រាសាទព្រៃបាសាក់នេះ។ ដោយឡែក សិលាចារឹកចំនួនពីរផ្ទាំងទៀត ចារឹកនៅដើមរាជ្យព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៦៨-១០០០) ដែលសុទ្ធសឹងរៀបរាប់អំពីមូលនិធិសម្រាប់ប្រាសាទ។ ហេតុដូច្នេះហើយ យោងតាមសិលាចារឹកទាំងបួនផ្ទាំងនេះ បានផ្ដល់ព័ត៌មានឱ្យគេអាចសន្និដ្ឋានបានថា ប្រាសាទព្រៃ

បាសាក់ ទំនងមានឈ្មោះដើមថា ""**វកកាកេស្វរ**" ឬ "**កំម្រតេង ជគត វក ឯក**" ប៉ុន្តែមិនបានផ្តល់ព័ត៌មានឱ្យដឹងថា បដិមាទេពប្រុសដែលយើងលើកមកសិក្សានេះគឺពិតជា "ព្រះសិវ" ឬមិនមែននោះឡើយ ព្រោះមិនមានសិលាចារឹកណាមួយបានរៀបរាប់អំពីបដិមានេះឡើយ។ រីឯការដែលអ្នកសិក្សាស្រាវជ្រាវជំនាន់មុនយល់ថា បដិមាទេពប្រុសនេះ គឺជា "**ព្រះសិវ**" គឺគេយោងទៅលើនៅលើថ្ងាសមានព្រះនេត្រទី៣ និងអង្គុយក្នុងទម្រង់ជា "មហារាជលីលសន" ដែលជាកាយវិការអង្គុយបែបខ្ពង់ខ្ពស់ និងជាកាយវិការគេនិយមបង្ហាញអំពីព្រះសិវ។ ទោះបីជាយ៉ាងណាក៏ដោយឆ្លងតាមសិលាចារឹកទាំងបួនផ្ទាំងនេះ ក៏អាចឱ្យគេដឹងបានថា បដិមានេះ ទំនងកសាងឡើងនៅរវាងស.វ.ទី១០ ឬទី១១ ពោល គឺអាចនៅក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន ព្រះបាទជ័យវរ្ម័នទី៥ ឬព្រះបាទសូរ្យវរ្ម័ន។

ជារួមមក តាមរយៈការវិភាគលើទិន្នន័យបុរាណវិទ្យា និងសិលាចារឹកដែលរកឃើញនៅប្រាសាទព្រៃប្រាសាក់ គេអាចទាញសេចក្តីសន្និដ្ឋានបានថា បដិមាទេពប្រុសដែលរកឃើញដោយលោក Jean Commaille គឺមិនមានភស្តុតាងសិលាចារឹកណាមួយបញ្ជាក់ចំព្រះនាមច្បាស់លាស់អំពីអត្តសញ្ញាណនៃបដិមានេះនោះទេ។ ប៉ុន្តែ តាមលក្ខណៈរូបសាស្ត្រ ដោយផ្អែកលើកាយវិការ "មហារាជលីលាសន" និងការមានព្រះនេត្រទីបីនៅលើថ្ងាស បានផ្តល់ទម្ងន់មួយដល់ការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវជំនាន់មុនថា បដិមានេះតំណាងឱ្យព្រះសិវក្នុងទម្រង់ជារាជវង្ស។ លើសពីនេះចំពោះអាយុកាលរបស់បដិមា គឺអាចកសាងឡើងនៅរវាងស.វ.ទី១០ ឬទី១១ ចាប់ពីរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន ដល់រាជ្យព្រះបាទសូរ្យវរ្ម័នទី១។ ក្នុងនោះ អ្នកស្រាវជ្រាវមុនៗយល់ស្របគ្នាថា បដិមានេះអាចស្ថិតនៅក្នុងរចនាបថឃ្លាំង ឬបាភួន ក្នុងអំឡុងពាក់កណ្តាលទី២ នៃស.វ.ទី១១ រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១។ ការរកឃើញនេះមិនត្រឹមតែឆ្លុះបញ្ចាំងពីឥទ្ធិពលនៃព្រហ្មញ្ញសាសនា និងការគោរពបូជាព្រះសិវនៅក្នុងតំបន់ស្វាយរៀងនាសម័យបុរាណប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាភស្តុតាងបង្ហាញពីទំនាក់ទំនងនយោបាយ និងសាសនារវាងរាជធានីអង្គរ និងតំបន់ជាយដែននៃអាណាចក្រខ្មែរផង។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## បញ្ជីឯកសារពិគ្រោះ


Aymonier, É., 1900. *Le Cambodge,* Tome I, Paris.

Boisselier, J., 1955. *La statuaire khmère et son évolution*. Saigon: École française d'Extrême-Orient.

Coedès, G., 1950. *Inscription du Cambodge*, Volume II, Hanoi.

Coedès, G., 1954. *Inscription du Cambodge*, Volume VI, Hanoi.

Coedès, G., 1966. *Inscription du Cambodge*, Volume VIII, Hanoi.

Commaille, J., 1902. Les ruines de Bassac (Cambodge). *Bulletin de l'École française d'Extrême-Orient*, 2(1), pp. 260–267. Available at: https://doi.org/10.3406/befeo.1902.1142

Dalsheimer, N., 2001. *Les collections du musée national de Phnom Penh*. Paris: École française d'Extrême-Orient.

Lajonquière, L., 1902. *Inventaire descriptif des monuments du Cambodge*. Paris.


## Abstract

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ១៖ ប្រាសាទបាសាក់ បន្ទាប់ពីការកំណាយបុរាណវិទ្យា នៅឆ្នាំ១៩០១ - ១៩០២ (រូបថត៖ EFEO)





រូបលេខ២-៣៖ បដិមាទេពប្រុស (ព្រះសិវ) តម្កល់នៅសាលាខេត្តស្វាយរៀង នៅឆ្នាំ១៩០២ (រូបថត៖ EFEO)

អត្ថបទដោយ៖ ម៉ន់ វ៉ាលី



រូបលេខ២៤៖ បដិមាទេពប្រុស (ព្រះសិវ) តម្កល់នៅសារមន្ទីរជាតិកម្ពុជា នាទ.ស.១៩២០ (?)  (រូបថត៖ EFEO)





រូបលេខ២៥-៦៖ បដិមាទេពប្រុស (ព្រះសិវ) តម្កល់នៅសារមន្ទីរជាតិកម្ពុជា នាសម័យបច្ចុប្បន្ន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី